# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ......០១ សរា...

## សារាចរ

## ស្តីពី

## ការផ្តល់របាយការណ៍ អំពីសកម្មភាពការងាររបស់ ក្រសួង ស្ថាប័ន និងខេត្ត ក្រុង

កន្លងមករាជរដ្ឋាភិបាលបានបំពេញភារកិច្ចរៀបចំចងក្រងជារបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ខ្លួនលើគ្រប់វិស័យប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងឆ្នាំ ថ្វាយព្រះមហាក្សត្រ និងជូនស្ថាប័ននីតិប្បញ្ញត្តិបានទៀងទាត់តាមកាលកំណត់គួរជាទីមោទនៈ។ សមិទ្ធផលដែលរាជរដ្ឋាភិបាលសម្រេចបាននេះ បានមកពីការយកចិត្តទុកដាក់ចូលរួមផ្តល់របាយការណ៍យ៉ាងសកម្ម និងទៀងទាត់ពីក្រសួង ស្ថាប័ន និងខេត្ត ក្រុង។ ក៏ប៉ុន្តែទន្ទឹមនេះ នៅមានក្រសួង ស្ថាប័ន និងខេត្ត ក្រុងមួយចំនួន ពុំទាន់យកចិត្តទុកដាក់ក្នុងការផ្តល់របាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួន ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងឆ្នាំ មកទីស្តីការគណៈរដ្ឋមន្ត្រីនៅឡើយ ដែលជាហេតុធ្វើឱ្យរបាយការណ៍របស់រាជរដ្ឋាភិបាលមានខ្លឹមសារ និងទិន្នន័យមិនទាន់គ្រប់គ្រាន់តាមលទ្ធផល និងសមិទ្ធផលជាក់ស្តែង ទោះបីជារាជរដ្ឋាភិបាលបានចេញលិខិតជូនដំណឹងក្រើនរំឭកជាច្រើនលើករួចមកហើយក៏ដោយ។

ម្យ៉ាងវិញទៀត ក្នុងឱកាសបំពេញទស្សនកិច្ចជាផ្លូវការរបស់គណៈប្រតិភូថ្នាក់ដឹកនាំរដ្ឋាភិបាលបរទេសនៅព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាទស្សនកិច្ចជាផ្លូវការរបស់គណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជានៅបរទេស រាជរដ្ឋាភិបាលត្រូវការចាំបាច់ នូវរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការ ឬឯកសារផ្សេងៗដែលក្រសួង ស្ថាប័ន និងខេត្ត ក្រុងសាមី បានចុះហត្ថលេខាជាមួយប្រទេសនានា ឬអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ឬជាមួយខេត្ត ក្រុងជាប់ព្រំដែននៃបណ្តាប្រទេសជាមិត្ត សម្រាប់ជាជំនួយស្មារតីក្នុងការពិភាក្សាជាមួយគណៈប្រតិភូរដ្ឋាភិបាលបរទេស។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់ខាងលើ និងដើម្បីរំលេចឱ្យឃើញនូវស្នាដៃការងាររបស់ក្រសួង ស្ថាប័ន និងខេត្ត ក្រុង ដែលបានខិតខំយកចិត្តទុកដាក់អនុវត្តតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី ៣ នៃរដ្ឋសភា រាជរដ្ឋាភិបាលធ្វើការណែនាំដូចតទៅ :

១-គ្រប់ក្រសួង ស្ថាប័ន ត្រូវបង្កើតយន្តការមួយដែលមានមន្ត្រីបំពេញការងារជាអចិន្ត្រៃយ៍ ដើម្បីបូកសរុបសកម្មភាពការងាររបស់ខ្លួន ឱ្យមានខ្លឹមសារ និងទិន្នន័យគ្រប់ជ្រុងជ្រោយ ដោយឆ្លុះបញ្ចាំងនូវលទ្ធផល និងសមិទ្ធផលទាំងអស់នៃការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល រួចផ្ញើមកទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងផែនការ ឱ្យបានទៀងទាត់តាមកាលបរិច្ឆេទកំណត់ ដូចខាងក្រោម ៖

-របាយការណ៍ប្រចាំខែ សប្តាហ៍ទី១ នៃខែបន្ទាប់
-របាយការណ៍ប្រចាំត្រីមាស សប្តាហ៍ទី១ នៃខែមេសា
-របាយការណ៍ប្រចាំឆមាស សប្តាហ៍ទី១ នៃខែកក្កដា
-របាយការណ៍ប្រចាំ៩ខែ សប្តាហ៍ទី១ នៃខែតុលា
-របាយការណ៍ប្រចាំឆ្នាំ សប្តាហ៍ទី២ នៃខែធ្នូ ។

២-គ្រប់ខេត្ត ក្រុង ត្រូវបង្កើតយន្តការមួយ ដែលមានមន្ត្រីបំពេញការងារជាអចិន្ត្រៃយ៍ ដើម្បីបូកសរុបសកម្មភាពការងាររបស់ខ្លួន ឱ្យមានខ្លឹមសារ និងទិន្នន័យគ្រប់ជ្រុងជ្រោយ ដោយឆ្លុះបញ្ចាំងនូវលទ្ធផល និងសមិទ្ធផលទាំងអស់នៃការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល រួចផ្ញើមកក្រសួងមហាផ្ទៃ ដោយចម្លងជូនទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងផែនការ ។

៣-គ្រប់ក្រសួង ស្ថាប័ន និងខេត្ត ក្រុងពាក់ព័ន្ធ ត្រូវបញ្ជូនមកក្រសួងការបរទេស និងសហប្រតិបត្តិ-ការអន្តរជាតិ ដោយចម្លងជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងក្រសួងផែនការ នូវរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិ ឬការចុះហត្ថលេខាលើឯកសារផ្សេងៗជាមួយខេត្ត ក្រុងជាប់ព្រំដែននៃបណ្តាប្រទេសជាមិត្ត ឬក៏ប្រទេសនានា ឬអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ដើម្បីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងក្រសួងផែនការ បូកសរុបជូនរាជ-រដ្ឋាភិបាលបានទាន់ពេលវេលា ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន និងខេត្ត ក្រុងទាំងអស់ ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យសម្រេចបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ